**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ៤៣៣/២០ ក.ប/ប្រ.ក.ខ.ល

# ប្រកាស
## ស្តីពី
## កិច្ចព្រមព្រៀងរវាងនាយកដ្ឋានពេទ្យការងារ និងមូលដ្ឋានសុខាភិបាល ក្នុងការផ្តល់សេវាពិនិត្យសុខភាពដល់កម្មករនិយោជិតខ្មែរ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងប្រកាសលេខ៤២៩/២០ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ
- តាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .–**

ប្រកាសនេះ មានគោលបំណងកំណត់បែបបទ និងនីតិវិធីនៃការចុះកិច្ចព្រមព្រៀងរវាងនាយកដ្ឋានពេទ្យការងារ និងមូលដ្ឋានសុខាភិបាលក្នុងការផ្តល់សេវាពិនិត្យសុខភាពដល់កម្មករនិយោជិតខ្មែរ។

**ប្រការ២ .–**

មូលដ្ឋានសុខាភិបាលដែលមានបំណងផ្តល់សេវាពិនិត្យសុខភាពកម្មករនិយោជិតខ្មែរ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. ត្រូវចុះកិច្ចព្រមព្រៀងជាមួយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុវត្តតាមទម្រង់កិច្ចព្រមព្រៀងដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

២. ត្រូវមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងសុខាភិបាល និងត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតផ្តល់សេវា និងគុណភាពសេវាពីនាយកដ្ឋានពេទ្យការងារ។

៣. មានទីតាំងភូមិសាស្ត្រ ស្ថានភាព និងហេដ្ឋារចនាសម្ព័ន្ធសមស្រប ឬគ្រប់គ្រាន់ សម្រាប់ផ្តល់សេវាពិនិត្យសុខភាព ឱ្យមានគុណភាពស្របតាមលក្ខខណ្ឌកំណត់ដោយនាយកដ្ឋានពេទ្យការងារ រួមមាន៖

- អគារសមរម្យ និងបរិស្ថានអនាម័យល្អ
- សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យ និងមធ្យោបាយស្តង់ដាចាំបាច់នានា សម្រាប់គាំទ្រដល់ការពិនិត្យកាយសម្បទា
- បុគ្គលិកសុខាភិបាល មានសមត្ថភាពបច្ចេកទេស ក្រមសីលធម៌ និងចំនួនសមស្របតាមការកំណត់របស់ក្រសួងសុខាភិបាល។

**ប្រការ៣ .-**

នាយកដ្ឋានពេទ្យការងារ ត្រូវពិនិត្យតាមដានគុណភាពសេវាពិនិត្យសុខភាពនៃមូលដ្ឋានសុខាភិបាលដៃគូដោយសហការផ្តល់ព័ត៌មានទៅវិញទៅមក ដើម្បីលើកកម្ពស់គុណភាពសេវាជាប្រចាំ និងតម្រង់ទិសនៃការប្រើប្រាស់សេវាឱ្យមានប្រសិទ្ធភាព។

**ប្រការ៤ .-**

នាយកដ្ឋានពេទ្យការងារ និងមូលដ្ឋានសុខាភិបាលដៃគូ អាចធ្វើការពិនិត្យ និងបន្តកិច្ចព្រមព្រៀងជាថ្មីដោយផ្អែកលើគុណភាពសេវា និងកម្រិតផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដៃគូ។ នាយកដ្ឋានពេទ្យការងារមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលដៃគូដែលមិនបានអនុវត្តតាមលក្ខខណ្ឌកំណត់ និងបទប្បញ្ញត្តិច្បាប់ជាធរមាន។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានពេទ្យការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៣៣/២០ កប/ប្រក.ខ.ល ចុះថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ២០២០ ស្ដីពីកិច្ចព្រមព្រៀងរវាងនាយកដ្ឋានពេទ្យការងារ និងមូលដ្ឋានសុខាភិបាល ក្នុងការផ្តល់សេវាពិនិត្យ សុខភាពដល់កម្មករនិយោជិតខ្មែរ

# កិច្ចព្រមព្រៀងក្នុងការផ្តល់សេវាពិនិត្យសុខភាពដល់កម្មករនិយោជិតខ្មែរ
# រវាង
# នាយកដ្ឋានពេទ្យការងារ
# និង
# មូលដ្ឋានសុខាភិបាល.........................................

កិច្ចព្រមព្រៀងក្នុងការផ្តល់សេវាពិនិត្យសុខភាពដល់កម្មករនិយោជិតខ្មែរ ត្រូវបានធ្វើឡើងរវាង៖

**នាយកដ្ឋានពេទ្យការងារ** មានទីតាំងស្ថិតនៅអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលតទៅនេះហៅថា **ភាគី "ក"** ។

និង

**មូលដ្ឋានសុខាភិបាល**...........................................មានទីតាំងស្ថិតនៅអគារលេខ.............. ភូមិ...........................ឃុំ/សង្កាត់...................................ស្រុក/ខណ្ឌ/ក្រុង....................................... រាជធានី/ខេត្ត.................................. ដែលតទៅនេះហៅថា **ភាគី "ខ"** ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

## ប្រការ១ ._ គោលបំណង

- គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីកំណត់នូវតួនាទីភារកិច្ច និងលក្ខខណ្ឌដែលត្រូវអនុវត្តដោយ **ភាគី "ក"** និង **ភាគី "ខ"** ក្នុងការផ្តល់សេវាពិនិត្យសុខភាពដល់កម្មករនិយោជិតខ្មែរ។

## ប្រការ២ ._ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ភាគី "ក"

- កំណត់លក្ខខណ្ឌ និងទម្រង់នៃការពិនិត្យសុខភាពកម្មករនិយោជិត ដល់មូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង
- ធ្វើការស្ទង់មតិពីភាពពេញចិត្តរបស់កម្មករនិយោជិតចំពោះសេវា **ភាគី "ខ"** និងផ្តល់ព័ត៌មានត្រឡប់ទៅ **ភាគី "ខ"** អំពីលទ្ធផលនៃការស្ទង់មតិនោះ

- ធ្វើការពិនិត្យលក្ខខណ្ឌបច្ចេកទេសរបស់មូលដ្ឋានសុខាភិបាល ក្នុងការផ្តល់សេវាពិនិត្យសុខភាពឱ្យមានគុណភាព
- រៀបចំប្រជុំជាមួយ **ភាគី "ខ"** ឱ្យបានមួយដងយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីពិភាក្សារកដំណោះស្រាយអំពីបញ្ហាផ្តល់សេវាពិនិត្យសុខភាព និងបញ្ហាប្រឈមនានា ដែលបានជួបប្រទះ។
- រៀបចំបុគ្គលិកគ្រប់គ្រាន់នៅប្រចាំការ ដើម្បីបំពេញការងារប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌
- ផ្តល់សេវាកម្ម ប្រកបដោយគុណភាព និងសុវត្ថិភាពខ្ពស់ស្របតាមស្តង់ដាវេជ្ជសាស្ត្រ រយៈពេលរង់ចាំទទួលការពិនិត្យសុខភាពមិនត្រូវយឺតយូរ និងគ្មានហេតុផល បន្ទាប់ពីកម្មករនិយោជិតចូលមកដល់មូលដ្ឋានសុខាភិបាល
- ផ្តល់របាយការណ៍ នៃលទ្ធផលពិនិត្យសុខភាពជូនដល់កម្មករនិយោជិតវិញ ក្នុងអំឡុងពេល ៣(បី)ថ្ងៃនៃថ្ងៃធ្វើការ
- ធ្វើរបាយការណ៍សរុប ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជាលាយលក្ខណ៍អក្សរផ្ញើមកនាយកដ្ឋានពេទ្យការងារ
- ការពិនិត្យកម្មករនិយោជិត ត្រូវអនុវត្តតាមការកំណត់នៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ។

## ប្រការ៣ ._ វិសោធនកម្ម និងការដោះស្រាយវិវាទ

- កិច្ចព្រមព្រៀងនេះមានរយៈពេល ២ (ពីរ) ឆ្នាំ និងអាចបន្តបានដោយការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់គូភាគី
- វិសោធនកម្មនៃកិច្ចព្រមព្រៀងនេះអាចធ្វើទៅបាន តាមរយៈការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់គូភាគី
- វិវាទទាំងឡាយណាដែលកើតចេញពីការបកស្រាយ ឬការអនុវត្តបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ គូភាគីត្រូវដោះស្រាយប្រកបដោយស្មារតីយោគយល់គ្នាទៅវិញទៅមកតាមរយៈការពិភាក្សា ឬមធ្យោបាយផ្សេងទៀត តាមការព្រមព្រៀងគ្នា
- កិច្ចព្រមព្រៀងនេះ អាចត្រូវបានព្យួរ ឬបញ្ចប់តាមការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សររបស់ គូភាគី។ **ភាគី "ក"** អាចព្យួរ ឬបញ្ចប់កិច្ចព្រមព្រៀងនេះដោយឯកតោភាគី ដោយឈរលើមូលដ្ឋាននៃការព្យួរ ឬការលុបអាជ្ញាប័ណ្ណការធ្វើសកម្មភាពខុសច្បាប់ណាមួយដែលមានចែងក្នុងច្បាប់ជាធរមាន ឬដោយហេតុផលសមស្របណាមួយរបស់ **ភាគី "ខ"**
- **ភាគី "ក"** មានសិទ្ធិរំលាយកិច្ចព្រមព្រៀង ក្នុងករណី **ភាគី "ខ"** មិនអនុវត្តតាមតួនាទី ភារកិច្ច ដូចមានចែងក្នុងប្រការ៣ ដោយមានការជូនដំណឹងទៅ **ភាគី "ខ"** ឱ្យបានមុន ១៥ (ដប់ប្រាំ) ថ្ងៃ។
- **ភាគី "ខ"** មានសិទ្ធិស្នើសុំរំលាយកិច្ចព្រមព្រៀងជាមួយ **ភាគី "ក"** ដោយមានហេតុផលសមស្រប និងធ្វើការជូនដំណឹងជាមុនក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។

**ប្រការ៤ ._ ប្រសិទ្ធភាពនៃកិច្ចព្រមព្រៀង**

- កិច្ចព្រមព្រៀងនេះ ត្រូវធ្វើជាចំនួន ២ (ពីរ) ច្បាប់ ជាភាសាខ្មែរ ហើយមានតម្លៃស្មើគ្នានៅចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**នាយកដ្ឋានពេទ្យការខារ** **មូលដ្ឋានសុខាភិបាល.....................**